# ធនាគារជាតិនៃកម្ពុជា



ធនាគារជាតិនៃកម្ពុជា សាខាខេត្តក្រចេះ

# របាយការណ៍ប្រចាំឆ្នាំ ២០០៩

## នាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



របាយការណ៍នេះរៀបចំឡើងដើម្បីបង្ហាញអំពីការរីកចម្រើននៅក្នុងប្រព័ន្ធធនាគារ ទោះបីជាសេដ្ឋកិច្ចកម្ពុជាកំពុងតែពុះពារងើបឡើងពីវិបត្តិសេដ្ឋកិច្ចសកល។ ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនជាបណ្តើរៗនៅក្នុងឆ្នាំ២០០៩ អាស្រ័យដោយមានការបង្កើតធនាគារថ្មី សាខាថ្មី និងបុត្រសម្ព័ន្ធថ្មី។ ការបង្កើតឡើងទាំងនេះជាសក្ខីភាពបង្ហាញអំពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណៈជន ក៏ដូចជាវិនិយោគិនមកលើប្រព័ន្ធធនាគារនៅកម្ពុជា។

នៅក្នុងឆ្នាំ ២០០៩ ធនាគារថ្មីចំនួន ៣បានចាប់ផ្តើមធ្វើប្រតិបត្តិការ និងសាខាថ្មីចំនួន ២២ ថែមទៀតបានពង្រីកប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចជុំវិញរាជធានីភ្នំពេញ និងខេត្តសំខាន់ៗមួយចំនួន។ ដោយមានការកើនឡើងនូវចំនួនធនាគារ ផលិតផល សេវាកម្ម និងបណ្តាញប្រតិបត្តិការត្រូវបានអភិវឌ្ឍ និងពង្រីកបន្ថែមទៀត។ ប្រជាពលរដ្ឋដែលមិនធ្លាប់បានប្រើប្រាស់សេវាកម្មធនាគារពីមុនមក អាចមានលទ្ធភាពទទួលយកសេវានេះបានប្រសើរជាងមុន។ ប្រព័ន្ធធនាគារបានវិវត្តន៍ពីប្រតិបត្តិការដែលមានភាពសាមញ្ញទៅប្រតិបត្តិការដែលមានភាពស្មុគស្មាញជាបណ្តើរៗ។ ការដាក់ឲ្យប្រើប្រាស់នូវសេវាកម្មផ្ទេរប្រាក់ចល័ត ក៏បានជួយជំរុញ និងបង្កើនការចូលរួមនៅក្នុងប្រព័ន្ធធនាគារ។ ការអភិវឌ្ឍន៍នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក៏មានសន្ទុះខ្លាំងក្លាផងដែរចាប់តាំងពីមានការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពី ការអនុញ្ញាតឲ្យស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ បច្ចុប្បន្នមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ បានទទួលអាជ្ញាបណ្ណ ទទួលប្រាក់បញ្ញើពីសាធារណៈជន។

ប្រតិបត្តិការនៅក្នុងប្រព័ន្ធធនាគារនៅក្នុងឆ្នាំ២០០៩ បានទទួលរងផលប៉ះពាល់ខ្លះពីវិបត្តិសេដ្ឋកិច្ចសកល។ អន្តរការីយកម្មនៅក្នុងប្រព័ន្ធធនាគារបានថយចុះ ដោយសារការធ្លាក់ចុះកំណើនឥណទានមកត្រឹម ៣%។ ដោយឡែក ប្រាក់បញ្ញើអតិថិជនមានកំណើន ៣២% ដែលបានចូលរួមយ៉ាងខ្លាំងធ្វើឲ្យកំណើនទ្រព្យសកម្មចំនួន ២០%។ សូចនាករពីលទ្ធភាពស្វែងរកប្រាក់ចំណេញ មាននិន្នាការធ្លាក់ចុះដោយសារសកម្មភាពសេដ្ឋកិច្ចមិនសូវមានភាពមមាញឹក ជាពិសេសការវិនិយោគ និងការប្រើប្រាស់មានការធ្លាក់ចុះ។ ទោះបីជាមានការធ្លាក់ចុះនេះក៏ដោយ អនុបាតប្រុងប្រយ័ត្ននៃប្រព័ន្ធធនាគារបានបង្ហាញពីស្ថានភាពសុខុមាលភាពប្រសើរជាងមុនដូចជា សាធនភាព សាច់ប្រាក់ងាយស្រួល ទោះបីជាឥណទានមិនដំណើរការបានកើនឡើងបន្តិចបន្តួចក៏ដោយ។

ស្របជាមួយនឹងការរីកចម្រើននៅក្នុងប្រតិបត្តិការធនាគារ ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរអាណាព្យាបាល បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីរក្សាស្ថិរភាពនៅក្នុងប្រព័ន្ធធនាគារដូចជា ការពង្រឹងដើមទុន រចនាសម្ព័ន្ធអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ ជាពិសេសហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការអនុវត្តន៍តាម។ ជាលទ្ធផល សុខុមាលភាពរបស់

គ្រឹះស្ថានធនាគារបានត្រូវលើកកំពស់ ហើយបច្ចុប្បន្នមានភាពរឹងមាំគ្រប់គ្រាន់ ក្នុងការទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចសកល។ ចំពោះការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ឧបករណ៍គោលនយោបាយដែលមានភាពទន់ភ្លន់ ជាពិសេស ប្រាក់បម្រុងកាតព្វកិច្ច និងការគ្រប់គ្រងការប្តូរប្រាក់ជាកត្តាឈានមុខគេក្នុងការជំរុញឲ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ការបញ្ចូលលំហូរសាច់ប្រាក់ងាយស្រួលនៅក្នុងប្រព័ន្ធធនាគារ នៅតែជាអាទិភាពក្នុងការជំរុញការវិនិយោគ និងការងើបឡើងវិញនៃសេដ្ឋកិច្ចជាតិ។

ទន្ទឹមនឹងតួនាទីចម្បងក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏ប្តេជ្ញាលើកកម្ពស់ការប្រតិបត្តិឲ្យស្របជាមួយនឹងគោលការណ៍ និងការអនុវត្តន៍ជាអន្តរជាតិ។ ដោយសារវិស័យហិរញ្ញវត្ថុនៅកម្ពុជាស្ថិតក្នុងដំណាក់កាលក្មេងខ្ចីនៅឡើយ គោលដៅចម្បងនាពេលបច្ចុប្បន្នក្នុងការពង្រឹងសមត្ថភាពត្រួតពិនិត្យគឺ ត្រូវសម្រេចឲ្យបាននូវការអនុវត្តន៍តាមគោលការណ៍ស្នូល របស់បាសែលក្នុងការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ខណៈពេលដែលការអនុវត្តន៍បាសែលទី២ គឺជាចក្ខុវិស័យសម្រាប់រយៈពេលវែង។ គោលការណ៍ទាំងនេះ បានដើរតួនាទីជាផែនការចង្អុលទិស សម្រាប់ធនាគារជាតិនៃកម្ពុជាធ្វើដំណើរឆ្ពោះទៅមុខ ឲ្យស្របតាមបទដ្ឋានក្នុងតំបន់ ក៏ដូចជាអន្តរជាតិ។ បន្ថែមពីនេះការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបញ្ញត្តិករជាប្រចាំនៅតែមានសារៈសំខាន់ក្នុងការសម្រេចគោលដៅនេះ។ ការបណ្តុះបណ្តាលទាំងក្នុងស្រុក និងក្រៅស្រុកត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដោយមានជំនួយឧបត្ថម្ភពីស្ថាប័នអន្តរជាតិសំខាន់ៗដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី វិទ្យាស្ថានស៊ាសិន និងធនាគារកណ្តាលនៃប្រទេសជាច្រើនទៀត។

របាយការណ៍នេះមានគោលដៅលើកកម្ពស់តម្លាភាព នៅក្នុងវិស័យធនាគារតាមរយៈការផ្តល់ព័ត៌មានសំខាន់ៗ ទៅកាន់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីពិនិត្យពីស្ថានភាពហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធធនាគារទាំងមូលក៏ដូចជាគ្រឹះស្ថានធនាគារនីមួយៗ។ ដោយសារព័ត៌មានអាចស្វែងរកបានដោយងាយ គ្រប់ភាគីពាក់ព័ន្ធទាំងអស់អាចរំពឹងទុកថានឹងអាចដាក់វិន័យកម្មទីផ្សារលើប្រតិបត្តិការរបស់ធនាគារ ដែលនឹងជំរុញការប្រកួតប្រជែង ការប្រតិបត្តិដោយស្មើភាព និងបង្កើតនិយាមសមស្របនៅក្នុងវិស័យធនាគារ សម្រាប់ជាផលប្រយោជន៍ដល់សាធារណៈជនទាំងអស់។

ភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១០

**ជា ចាន់តូ**
**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

# មាតិកា


១. សេចក្តីផ្តើម ........................................................................................................១

២. ប្រតិបត្តិការនៅក្នុងវិស័យធនាគារ ...............................................................................១

២.១. កំណើនទ្រព្យសកម្ម ..........................................................................................២

២.២. កំណើនឥណទាន ...............................................................................................២

២.៣. កំណើនប្រាក់បញ្ញើ ..........................................................................................៣

៣. សូចនាករបទបញ្ញាប្រុងប្រយ័ត្នសំខាន់ៗ ......................................................................៣

៣.១. គុណភាពទ្រព្យសកម្ម ........................................................................................៣

៣.២. លទ្ធភាពស្វែងរកចំណេញ ..................................................................................៥

៣.៣. ភាពគ្រប់គ្រាន់នៃដើមទុន ..................................................................................៦

៣.៤. សាច់ប្រាក់ងាយស្រួល .......................................................................................៦

៣.៥. គុណភាពនៃការគ្រប់គ្រង ...................................................................................៧

៤. ការវិវត្តន៍មីក្រូហិរញ្ញវត្ថុ ............................................................................................៧

ឧបសម្ព័ន្ធទី១ : ទិន្នន័យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ឆ្នាំ ២០០៩......................១២

ឧបសម្ព័ន្ធទី២ : អត្រាការប្រាក់..................................................................................១៣

ឧបសម្ព័ន្ធទី៣ : ប្រព័ន្ធធនាគារនៅកម្ពុជា......................................................................១៥

រាល់ទិន្នន័យដែលបង្ហាញនេះត្រូវបានរៀបចំ និងចងក្រងដោយ ធនាគារជាតិនៃកម្ពុជា។
ចំណែកទិន្នន័យ GDP ទទួលបានពីខាងវិទ្យាស្ថានផែនការ និងស្ថិតិ។

## ១. សេចក្តីផ្តើម

ឆ្នាំ២០០៩ ជាឆ្នាំមួយដែលមានការប្រឈមចំពោះការរីកចម្រើននៅក្នុងប្រព័ន្ធធនាគារ។ ទោះបីជាមានការធ្លាក់ចុះនៃប្រាក់បញ្ញើ និងឥណទានរបស់អតិថិជនក៏ដោយ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលស្ថិតនៅក្នុងកម្រិតមួយ ដែលអាចគ្រប់គ្រងបានសម្រាប់វិស័យធនាគារ។ ជំនឿទុកចិត្តរបស់សាធារណៈជនមកលើប្រព័ន្ធធនាគារនៅតែមានស្ថិរភាព ដោយសារប្រាក់បញ្ញើអតិថិជនបានកើនឡើង ៣២%នៅក្នុងឆ្នាំ២០០៩។

នៅដំណាច់ឆ្នាំ២០០៩ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន ធនាគារពាណិជ្ជ ២៧ ធនាគារឯកទេស ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ២០ ដែលក្នុងនោះគ្រឹះស្ថានចំនួន ២ បានទទួលអាជ្ញាបណ្ណទទួលប្រាក់បញ្ញើ និងប្រតិបត្តិករឥណទានជនបទចុះបញ្ជីចំនួន ២៦។ មិនត្រឹមតែចំនួនគ្រឹះស្ថានធនាគារបានកើនឡើងនោះទេ ចំនួនបណ្តាញសាខានៅពាសពេញផ្ទៃប្រទេសបានពង្រីកយ៉ាងឆាប់រហ័សជាមួយនឹងការបង្កើតផលិតផល និងសេវាកម្មធនាគារជាច្រើនប្រភេទ។ កត្តាទាំងនេះបញ្ជាក់ពីការរីកចំរើនឥតឈប់ឈរនៃប្រព័ន្ធធនាគារនៅកម្ពុជា។

## ២. ប្រតិបត្តិការនៅក្នុងវិស័យធនាគារ

វិស័យធនាគារបានបន្តរីកចម្រើននៅក្នុងកម្រិតយឺតយ៉ាវនៅក្នុងឆ្នាំ ២០០៩ ដោយសារការធ្លាក់ចុះនៃវិស័យសំខាន់ៗមួយចំនួននៃសេដ្ឋកិច្ចកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ និងចំនួនអតិថិជនទទួលប្រាក់កម្ចីបានកើនឡើងយ៉ាងខ្លាំងក្លា ចំនួន ៣២% និង ១៤% រៀងគ្នា។ ប្រការនេះបង្ហាញអំពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណៈជនបន្ថែមទៀតមកលើប្រព័ន្ធធនាគារ ទោះបីជានៅក្នុងកំឡុងពេលទទួលរងផលប៉ះពាល់ពីវិបត្តិក៏ដោយ។ ការកើនឡើងនៃចំនួនអតិថិជនដាក់ប្រាក់បញ្ញើបណ្តាលមកពីការកើនឡើងតម្រូវការនៃការសន្សំ ការនាំមកនូវផលិតផលទំនើបទាន់សម័យ និងការរីកសាយភាយនៃសេវាកម្មធនាគារប្រកបដោយភាពងាយស្រួលនៅពាសពេញផ្ទៃប្រទេស។ ចំនួនអតិថិជនទទួលប្រាក់កម្ចីមានការកើនឡើងខ្ពស់នៅក្នុងត្រីមាសចុងក្រោយ នៅពេលដែលអាជីវកម្មនានាបានចាប់ផ្តើមមានសកម្មភាពមមាញឹកឡើងវិញ បន្ទាប់ពីបានធ្លាក់ចុះនៅពេលទទួលរងផលប៉ះពាល់នៃវិបត្តិ។ ប៉ុន្តែការកើនឡើងឥណទាន ថ្មីៗនេះត្រូវបានផ្តល់ឲ្យសម្រាប់តែអាជីវកម្មខ្នាតតូចនិងមធ្យម ខណៈពេលដែលគម្រោងវិនិយោគធំៗមានការកើនឡើងយឺតយ៉ាវនៅឡើយ។

រូបភាពទី១: ចំនួនអ្នកដាក់បញ្ញើ និងអ្នកទទួលឥណទាន



## ២.១ កំណើនទ្រព្យសកម្ម

រូបភាពទី២ : កំណើនទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារ




នៅដំណាច់ឆ្នាំ២០០៩ ទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារបានកើនឡើង ២០% ធ្លាក់ចុះពី ២៤% នៅក្នុងឆ្នាំ២០០៨។ ការកើនឡើងនេះបណ្តាលមកពីការកើនឡើងនៃដើមទុនធនាគារ ដែលទើបនឹងបង្កើតថ្មី និងកំណើនប្រាក់បញ្ញើរបស់អតិថិជន។ នៅក្នុងឆ្នាំនេះ ធនាគារពាណិជ្ជចំនួន ៣ បានទទួលអាជ្ញាបណ្ណ។

## ២.២ កំណើនឥណទាន

រូបភាពទី៣ : កំណើនឥណទាននៅក្នុងប្រព័ន្ធធនាគារ




កំណើនឥណទាននៅក្នុងប្រព័ន្ធធនាគារបានថយចុះមកត្រឹម ៥% នៅដំណាច់ឆ្នាំ២០០៩ ធៀបទៅនឹង៥៣% នៅឆ្នាំ២០០៨។ ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលបានកាត់បន្ថយតម្រូវការក្នុងការប្រើប្រាស់ និង ការវិនិយោគនៅក្នុងប្រទេស ដែលធ្វើឲ្យកំណើនឥណទានមានការធ្លាក់ចុះ។ ការដាក់ឲ្យប្រើប្រាស់នូវប្រកាសថ្មីស្តីពីចំណាត់ថ្នាក់ឥណទានក៏បានដាក់សម្ពាធដល់គ្រឹះស្ថានធនាគារក្នុងការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រក្នុងការផ្តល់ឥណទានរបស់ពួកគេ។ ការព្រួយបារម្ភអំពីកំណើនឥណទានមិនដំណើរការក៏បានរារាំងដល់គ្រឹះស្ថានធនាគារក្នុងការបញ្ចេញឥណទានថ្មីផងដែរ ។

## ២.៣ កំណើនប្រាក់បញ្ញើ

រូបភាពទី៤ : កំណើនប្រាក់បញ្ញើនៅក្នុងប្រព័ន្ធធនាគារ




បន្ទាប់ពីការធ្លាក់ចុះនូវកំណើននៅក្នុងឆ្នាំ២០០៨ ប្រាក់បញ្ញើអតិថិជននៅក្នុងប្រព័ន្ធធនាគារបានកើនឡើង ៣២%នៅក្នុងឆ្នាំ២០០៩។ ដោយសារការថយចុះនូវសកម្មភាពវិនិយោគ និងអវត្តមាននៃឧបករណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេស វិស័យធនាគារប្រមូលបានមូលនិធិដ៏ច្រើនសន្ធឹក។ ភាពមិនច្បាស់លាស់អំពីរយៈពេលនៃការធ្លាក់ចុះនៃវិបត្តិសេដ្ឋកិច្ចសកល ភ្នាក់ងារអាជីវកម្មនិងក្រុមគ្រួសារជ្រើសរើសយកការសន្សំជាងការវិនិយោគ។

# ៣. សូចនាករបទបញ្ញាប្រុងប្រយ័ត្នសំខាន់ៗ

## ៣.១ គុណភាពទ្រព្យសកម្ម

រូបភាពទី៥ : ឥណទានមិនដំណើរការនៅក្នុងប្រព័ន្ធធនាគារ




ឥណទានមិនដំណើរការនៅក្នុងប្រព័ន្ធធនាគារបានកើនឡើងបន្តិចពី ៣,៦៨% នៅក្នុងឆ្នាំ២០០៨ រហូតដល់ប្រមាណ ៥% នៅដំណាច់ឆ្នាំ២០០៩។ ការកើនឡើងនេះបណ្តាលមកពីមូលហេតុពីរយ៉ាង ។ មូលហេតុទី១ បណ្តាលមកពីឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចសកល។ វិស័យចម្បងៗនៅក្នុងសេដ្ឋកិច្ចដូចជា

វិស័យវាយនភ័ណ្ឌ ទេសចរណ៍ សំណង់ និងកសិកម្ម ត្រូវបានទទួលរងនូវវិបត្តិ។ អង្គភាពអាជីវកម្ម និង សហគ្រាសប្រកបរបរពាក់ព័ន្ធនឹងវិស័យទាំងនោះ បានពិនិត្យឃើញថាតម្រូវការនិងការប្រើប្រាស់មានការថយចុះ។ ហេតុនេះឥណទានធនាគារទៅកាន់វិស័យទាំងនោះបានជួបប្រទះនូវការទូទាត់សងយឺតយ៉ាវផងដែរ។ មូលហេតុទី២ បណ្តាលមកពីការដាក់ឲ្យប្រើប្រាស់នូវបទប្បញ្ញត្តិថ្មីស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាននៅដើមឆ្នាំ២០០៩ ដែលបានកំណត់លក្ខខណ្ឌវិនិច្ឆ័យតឹងរឹងជាងមុនក្នុងការទទួលស្គាល់ទ្រព្យសកម្មមានបញ្ហា។ បទប្បញ្ញត្តិនេះបានអនុវត្តពេញលេញនៅឆ្នាំ២០០៩ ដែលធ្វើឲ្យមានចំណាត់ថ្នាក់ឥណទានខ្ពស់ជាងមុន។

ទោះបីជាមាននិន្នាការកើនឡើងនៃឥណទានមិនដំណើរការតិចតួចយ៉ាងនេះក្តី ទ្រព្យសកម្មប្រមូលផ្តុំតាមរយៈ អត្ថគាហកៈតែមួយនិងទៅតាមវិស័យសេដ្ឋកិច្ចមិនមានបញ្ហាជាដុំកំភួននោះទេ។ ហានិភ័យឥណទានប្រមូលផ្តុំនៃអត្ថគាហកៈតែមួយសរុបបានធ្លាក់ចុះមកត្រឹម ៥៦% នៃមូលនិធិផ្ទាល់សុទ្ធនៅក្នុងឆ្នាំ២០០៩ ពី ៧៤% ក្នុងឆ្នាំ២០០៨ ដែលទាបជាងកម្រិតកំណត់៣០០%។ ការថយចុះនេះបណ្តាលមកពីការធ្លាក់ចុះកំណើនឥណទាននិងការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារ។ម្យ៉ាងវិញទៀត ហានិភ័យឥណទានធំលើអត្ថគាហកៈតែមួយ ត្រឹមកម្រិតកំណត់២០% និង៣៥% ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយគ្រឹះស្ថានធនាគារ ។

រូបភាពទី៦ : ឥណទានហានិភ័យធំ




នៅដំណាច់ឆ្នាំ២០០៩ ឥណទានប្រមូលផ្តុំតាមវិស័យសេដ្ឋកិច្ចបានបង្ហាញឲ្យឃើញថា វិស័យលក់រាយមានការប្រមូលផ្តុំឥណទានខ្ពស់បំផុត (១៨%នៃសំពៀតឥណទានសរុប) វិស័យលក់ដុំ (១៣%) និងវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន(១២%)។ វិស័យលក់រាយនិងលក់ដុំដែលរួមមានភាគច្រើនជាសហគ្រាសខ្នាតតូចនិងមធ្យមជាមូលដ្ឋានគ្រឹះនៃអាជីវកម្មឯកជននៅកម្ពុជា។ នៅពេលដែលមូលនិធិកាន់តែច្រើនត្រូវបានផ្តល់ទៅកាន់វិស័យទាំងនេះ ការងារកាន់តែច្រើនត្រូវបានបង្កើត និងធ្វើឲ្យកម្រិតចំណូលរបស់ក្រុមគ្រួសារកើនឡើងផងដែរ។ វិស័យអចលនទ្រព្យ និងសំណង់មានចំនួន ១៥% នៃសំពៀតឥណទានសរុប។ វិស័យទាំងនេះត្រូវបានចាត់ទុកថាជាវិស័យដែលមានហានិភ័យខ្ពស់ ហើយឥណទានដែលបានផ្តល់ទៅកាន់វិស័យទាំងនោះនឹងរំពឹងទុកថាមានការទូទាត់សងយឺតយ៉ាវមួយចំនួនផងដែរ។ ឥណទានប្រមូលផ្តុំនៅក្នុងវិស័យផ្សេងៗទៀតស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ។

## រូបភាពទី៦ : ឥណទានប្រមូលផ្តុំតាមវិស័យសេដ្ឋកិច្ច




## ៣.២ លទ្ធភាពស្វែងរកចំណេញ

### រូបភាពទី៧ : លទ្ធភាពស្វែងរកចំណេញនៅក្នុងប្រព័ន្ធធនាគារ




លទ្ធភាពស្វែងរកចំណេញរបស់ធនាគារមានការថយចុះច្រើនចាប់តាំងពីមានវិបត្តិសេដ្ឋកិច្ចសកល។ ចំណូលលើដើមទុនរបស់ធនាគារ បានធ្លាក់ចុះពីកំរិតខ្ពស់បំផុត ១៦.៥៨% នៅក្នុងឆ្នាំ២០០៧ មកត្រឹម ៥.៦៣% នៅក្នុងឆ្នាំ២០០៩។ ជាមួយគ្នានេះ ចំណូលលើទ្រព្យសកម្មបានធ្លាក់ចុះជាងពាក់កណ្តាលពី ២.៨៨% នៅក្នុងឆ្នាំ២០០៨ មក ១.២៥% នៅក្នុងឆ្នាំ២០០៩។ កត្តាជាច្រើនត្រូវបានចាត់ទុកថាជាមូលហេតុចំបងនៃការធ្លាក់ចុះនេះដូចជា ការថយចុះនៃកំណើនឥណទាន កំណើនតិចតួចនៃឥណទានមិនដំណើរការ ចំណាយបន្ថែមលើការប្រមូលប្រាក់បញ្ញើអតិថិជន និងការពង្រីកយ៉ាងឆាប់រហ័សនៃបណ្តាញសាខា។ នៅក្នុងឆ្នាំ២០០៩ សាខាធនាគារចំនួន២២ បានចាប់ផ្តើមដំណើរការអាជីវកម្ម។ ធនាគារមួយចំនួនធំបានងាកទៅរកប្រភពចំណូលមិនមែនការប្រាក់ដូចជា កំរៃជើងសារ និងសេវាកម្មផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យឥណទាន និងការចំណាយលើប្រភពទុន។

## ៣.៣ ភាពគ្រប់គ្រាន់នៃដើមទុន

រូបភាពទី៨ : ភាពគ្រប់គ្រាន់នៃដើមទុន និងសាច់ប្រាក់ងាយស្រួល




អនុបាតសាធនភាពនៅក្នុងប្រព័ន្ធធនាគារបានកើនទៅដល់៣២% នៅក្នុងឆ្នាំ២០០៩ ពី២៨% ក្នុងឆ្នាំ២០០៨។ ការធ្លាក់ចុះនៃកំណើនឥណទាន និងកំណើនវិនិយោគលើទ្រព្យសកម្មដែលមានហានិភ័យទាប ជាពិសេសប្រាក់បញ្ញើនៅធនាគារកណ្ដាលបានធ្វើឲ្យធ្លាក់ចុះចំនួនទ្រព្យសកម្មថ្លឹងតាមកម្រិតហានិភ័យ។ ជាងនេះទៀត ដើមទុនបន្ថែមពីធនាគារដែលទើបនឹងបង្កើតថ្មី និងការបង្កើនដើមទុនពីធនាគារដែលមានស្រាប់ ធ្វើឲ្យមូលដ្ឋានដើមទុនរបស់គ្រឹះស្ថានធនាគារកាន់តែមានភាពរឹងមាំថែមទៀត។ ជារួម កត្តាទាំងនេះបានធ្វើឲ្យអនុបាតសាធនភាពមានភាពប្រសើរឡើង។

## ៣.៤ សាច់ប្រាក់ងាយស្រួល

នៅក្នុងកំឡុងពេល ៥ឆ្នាំ កន្លងមកនេះ អនុបាតសាច់ប្រាក់ងាយស្រួលនៅក្នុងប្រព័ន្ធធនាគារ មាននិន្នាការធ្លាក់ចុះរហូតដល់ចំណុចទាបបំផុត ៨១% នៅក្នុងឆ្នាំ២០០៨ ធៀបទៅនឹងកម្រិតកំណត់បទបញ្ញាប្រុងប្រយ័ត្ន ៥០%។ ជាលើកដំបូងហើយដែលអនុបាតសាច់ប្រាក់ងាយស្រួលបានងើបឡើងវិញទៅដល់ ៩០% នៅដំណាច់ឆ្នាំ២០០៩។ កំណើននៃការផ្ដល់ឥណទានមានកម្រិតទាបជាងកំណើននៃប្រាក់បញ្ញើអតិថិជនដែលធ្វើឲ្យគ្រឹះស្ថានធនាគាររក្សាទុកទ្រព្យសកម្មងាយស្រួលច្រើនជាងមុន ហេតុនេះហើយធ្វើឲ្យអនុបាតសាច់ប្រាក់ងាយស្រួលមានការកើនឡើង។

រូបភាពទី៩ : អនុបាតទ្រព្យសកម្មងាយស្រួលធៀបនឹងប្រាក់បញ្ញើសរុប



### ៣.៥ គុណភាពនៃការគ្រប់គ្រង

ធនាគារជាតិនៃកម្ពុជាទទួលស្គាល់ថា ការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងគ្រឹះស្ថានធនាគារមានសារៈសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវភាពរឹងមាំ និងសុវត្ថិភាពនៅក្នុងប្រព័ន្ធធនាគារ។ បទប្បញ្ញត្តិថ្មីចំនួនពីរ ស្តីអំពីអភិបាលកិច្ច និងលក្ខណៈវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ត្រូវបានដាក់ឲ្យអនុវត្តនៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩។ បទប្បញ្ញត្តិស្តីពីអភិបាលកិច្ចមានទិសដៅបង្កើតរចនាសម្ព័ន្ធចាត់តាំងជាក់លាក់មួយនៅក្នុងគ្រឹះស្ថានធនាគារ ចំណែកបទប្បញ្ញត្តិស្តីពីលក្ខណៈវិនិច្ឆ័យត្រឹមត្រូវ និងសមស្របមានគោលដៅសំរិតសំរាំងយកបុគ្គលដែលមានសមត្ថភាព សុចរិត និងមានមូលធនគ្រប់គ្រាន់ចូលមកក្នុងប្រព័ន្ធធនាគារ។ បន្ទាប់ពីបានដាក់ឲ្យប្រើប្រាស់នូវបទប្បញ្ញត្តិទាំងនេះ ការគ្រប់គ្រង និងរចនាសម្ព័ន្ធចាត់តាំងនៅក្នុងគ្រឹះស្ថានធនាគារមានភាពប្រសើរឡើងជាលំដាប់។ ទោះជាយ៉ាងនេះក្តី មានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញដើម្បីពង្រឹងបទដ្ឋានគ្រប់គ្រងនៅក្នុងគ្រឹះស្ថានធនាគារឲ្យសមស្របទៅនឹងការអនុវត្តន៍ជាអន្តរជាតិ។ ធនាគារជាតិនៃកម្ពុជាបញ្ចប់សេចក្តីព្រាង និងរំពឹងដាក់ឲ្យប្រើប្រាស់នាពេលដ៏ខ្លីខាងមុខនូវបទប្បញ្ញត្តិបន្ថែមមួយចំនួនទៀតដូចជា បទប្បញ្ញត្តិស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនករឯករាជ្យ ដើម្បីលើកកម្ពស់តម្លាភាព និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

## ៤. ការវិវត្តន៍មីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ជាវិស័យមួយដែលបានចូលរួមចំណែក ក្នុងគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការកាត់បន្ថយភាពក្រីក្រ។ សម្ពាធនៃវិបត្តិជាសកលនាឆ្នាំកន្លងមកនេះបានធ្វើឲ្យវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាដែលស្ថិតនៅក្នុងប្រព័ន្ធតែមួយនៃវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរួម បានខិតខំពង្រឹងគុណភាពប្រតិបត្តិការរបស់ខ្លួន ដើម្បីអាចជំនះបាននូវភាពប្រឈមជាច្រើនដែលកើតមានក្នុងដំណាក់កាលនេះ។ ភាពជោគជ័យរបស់វិស័យមីក្រូហិរញ្ញវត្ថុមិនត្រឹមតែស្តែងឡើងតាមរយៈការរក្សាបាននូវចិរភាពរបស់គ្រឹះស្ថានដែលមានស្រាប់នោះទេ ប៉ុន្តែក៏មានការកើនឡើងនូវចំនួនអ្នកចូលរួមថ្មីផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីចំនួន ២ ត្រូវបានទទួលអាជ្ញាបណ្ណក្នុងឆ្នាំ២០០៩នេះ ដោយធ្វើឲ្យចំនួនសរុបរួមមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណចំនួន ២០ ដែលក្នុងនោះគ្រឹះស្ថានចំនួន ២ បានទទួលអាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន ២៦ និងអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើប្រតិបត្តិការផ្តល់សេវាហិរញ្ញវត្ថុជនបទចំនួនប្រមាណ 60។

គិតត្រឹមដំណាច់ឆ្នាំ២០០៩ សំពៀតឥណទានសរុបផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទកើនឡើងប្រមាណ ១០% បើធៀបទៅនឹងឆ្នាំ២០០៨ ដែលមានរហូតដល់ ៨១%។ អនុបាតឥណទានមិនដំណើរការបានកើនឡើងពីកម្រិតប្រមាណ ០.៤% ក្នុងឆ្នាំ២០០៨ ទៅកម្រិតប្រមាណ ២.៨០% ក្នុងឆ្នាំ២០០៩ ដែលនេះគឺបណ្តាលមកពីភាពថមថយនៃវិស័យសេដ្ឋកិច្ច និងការធ្លាក់ចុះនៃកំណើនឥណទាន។

## រូបភាពទី១១ : ឥណទានមិនដំណើរការ




ប្រជាពលរដ្ឋតាមតំបន់ជនបទនៅតែជាអតិថិជនគោលដៅ ក្នុងការទទួលយកសេវាចំបងពីរ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺ ឥណទាន និងគណនីសន្សំ។ នៅដំណាច់ឆ្នាំ២០០៩ អតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទមានចំនួន ៩០៨.២៩៨ នាក់ ដែលកើនឡើងប្រហែល ៦%។ សេវាឥណទានភាគច្រើន គឺផ្តល់ឲ្យដល់របរកសិកម្មដែលមានប្រមាណ ៤២% និងអាជីវកម្មខ្នាតតូច និងមធ្យមប្រមាណ ៣៥% នៃឥណទានសរុប។

## រូបភាពទី១២ : ភាគរយនៃចំណាត់ថ្នាក់ឥណទានតាមប្រភេទអាជីវកម្ម



ការដាក់ប្រាក់បញ្ញើរបស់អតិថិជនមានការកើនឡើងគួរឱ្យកត់សំគាល់។ គិតត្រឹមដំណាច់ឆ្នាំ ២០០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ បានទទួលប្រាក់បញ្ញើប្រមាណ ៤៤ ពាន់លានរៀល ពីអតិថិជន ចំនួន ១៧១.១៩០ នាក់ បើប្រៀបធៀបនឹងឆ្នាំ ២០០៨ ដែលចំនួនប្រាក់បញ្ញើ និងអ្នកដាក់ប្រាក់បញ្ញើមានប្រមាណ ២៦ពាន់លានរៀល និង ១៥៥.២៩១នាក់ រៀងគ្នា ហើយមានកំណើនប្រមាណ ៧២% និង១០% រៀងគ្នា។ ការកើនឡើងនេះអាស្រ័យដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ក្នុងចំណោមគ្រឹះស្ថានសរុបចំនួន ២០ បានទទួលអាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជន។ អាជ្ញាបណ្ណទទួលប្រាក់បញ្ញើពីសាធារណជន ត្រូវបានផ្តល់ឲ្យតែ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការបំពេញតាមលក្ខខណ្ឌ និងតម្រូវការ ដែលចែងក្នុងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាដល់សុវត្ថិភាពអ្នកដាក់ប្រាក់បញ្ញើ និងជំរុញជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធហិរញ្ញវត្ថុរួម។

រូបភាពទី១៣ : បំរែបំរួលនៃប្រាក់បញ្ញើសរុប និង ចំនួនអ្នកដាក់ប្រាក់បញ្ញើ (គិតជាលានរៀល)




ទ្រព្យសកម្មសរុបនៃវិស័យមីក្រូហិរញ្ញវត្ថុកើនឡើងប្រមាណ ១២% ពោលគឺទាបជាងកំណើនក្នុងឆ្នាំ ២០០៨ ដែលមានកម្រិតប្រមាណ ៨៧%។ ភាពថមថយនេះគឺដោយសារការធ្លាក់ចុះនៃប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

រូបភាពទី១៤ : ទ្រព្យសកម្មសរុប



គិតត្រឹមដំណាច់ឆ្នាំ ២០០៩ អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានកម្រិតប្រមាណ ២៤% ដែលខ្ពស់ជាងបទប្បញ្ញត្តិតម្រូវរបស់ធនាគារជាតិនៃកម្ពុជាដែលទាមទារឱ្យមានកម្រិតតិចបំផុត ១៥%។ អនុបាតសាធនភាពមានការកើនឡើងបន្តិចបើធៀបទៅនឹងចុងឆ្នាំ២០០៨ ដែលមានកម្រិតប្រមាណ ២០,៣៥%។ ការកើនឡើងអនុបាតសាធនភាពគឺដោយសារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការរឹតបន្តឹងលើទ្រព្យសកម្ម ដែលជាពិសេសទៅលើឥណទានក្នុងដំណាក់កាលវិបត្តិជាសកល។ ម៉្យាងវិញទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការបង្កើនដើមទុនរបស់គេបន្តិចម្តងៗ។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៨ មូលធនផ្ទាល់សុទ្ធរបស់វិស័យមីក្រូហិរញ្ញវត្ថុទាំងមូលមានការកើនឡើងប្រមាណ ៣៣% ដែលនេះក៏ជាកត្តាជំរុញឱ្យមានកំណើនអនុបាតសាធនភាពផងដែរ។

រូបភាពទី១៥ : អនុបាតសាធនភាព




អនុបាតសាច់ប្រាក់ងាយស្រួល ត្រូវបានវាស់វែងក្នុងន័យរក្សាសមត្ថភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការឆ្លើយតបតម្រូវការសាច់ប្រាក់បន្ទាន់។ ដោយគិតចាប់តាំងពី ឆ្នាំ២០០៦ ២០០៧ ២០០៨ និង២០០៩ នេះ អនុបាតសាច់ប្រាក់ងាយស្រួលរបស់វិស័យមីក្រូហិរញ្ញវត្ថុមានកម្រិតប្រមាណ ៤.០៥០% ២.៦១៣% ៦.០៩៩% និង ៣.៦២៤% រៀងគ្នា។ យោងតាមតួលេខនេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុមានសាច់ប្រាក់ងាយស្រួលខ្ពស់ គឺដោយសារមូលហេតុថាវិស័យនេះមិនទាន់អាចទាក់ទាញប្រាក់បញ្ញើពីសាធារណជនបានច្រើននៅឡើយ ហើយម៉្យាងទៀត ទ្រព្យសកម្មរបស់គ្រឹះស្ថានភាគច្រើនមានរយៈកាលខ្លីដែលអាចត្រូវបានចាត់ទុកជាសាច់ប្រាក់ងាយស្រួលសម្រាប់បម្រើឱ្យតម្រូវការបន្ទាន់របស់អតិថិជន។

រូបភាពទី១៦ : អនុបាតសាច់ប្រាក់ងាយស្រួល



ភាពប្រឈមដែលបានកើតឡើងក្នុងឆ្នាំ២០០៩នេះ បានបង្ហាញឱ្យឃើញផងដែរពីការលំបាកនៃការពឹងផ្អែកលើមូលធនបរទេសដែលផ្តល់ក្នុងទម្រង់ជាបំណុល និងជាជំនួយបន្តិចបន្តួច ដោយក្នុងនោះមូលធនទាំងអស់នោះមាន ការរឹតបន្តឹង និងមានតម្លៃខ្ពស់ជាងមុន។ ហេតុផលនេះ បានធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនមានការរឹតត្បិត ការផ្តល់ឥណទានរបស់ខ្លួន និងត្រៀមបម្រុងការសងត្រលប់ទៅឱ្យម្ចាស់បំណុលវិញ។ ដូចនេះ ការគៀងប្រមូលប្រាក់បញ្ញើក្នុងស្រុក សម្រាប់បម្រើដល់សេវាឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតែមានភាពចាំបាច់ចំពោះប្រភពទុនយូរអង្វែង និងស្ថិរភាពរបស់វិស័យមីក្រូហិរញ្ញវត្ថុ។

ជារួមវិស័យមីក្រូហិរញ្ញវត្ថុ នៅតែបន្តរួមចំណែកចំពោះគោលនយោបាយនៃការកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីសម្ពាធនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសកលបានគ្របដណ្តប់ស្ទើគ្រប់វិស័យជាអាទិភាពរបស់កម្ពុជា សំពៀតឥណទាន ទំហំប្រាក់បញ្ញើ ចំនួនអតិថិជន ទំហំនិងគុណភាពទ្រព្យសកម្ម និងជាពិសេសកម្រិតអនុបាតតម្រូវដោយធនាគារជាតិនៃកម្ពុជា បានបង្ហាញនូវសញ្ញាដែលគួរឲ្យជឿជាក់បាន។ ស្នាដៃទាំងនេះបានកើតឡើងចេញពីការប្រឹងប្រែងរួមគ្នារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អតិថិជនតាមតំបន់ជនបទ អាជ្ញាធរមូលដ្ឋាន និងជាពិសេសធនាគារជាតិនៃកម្ពុជា។ ម៉្យាងវិញទៀត លទ្ធផលទាំងអស់នេះ ក៏មិនអាចកាត់ផ្តាច់បានពីបរិស្ថានអំណោយផលដែលកើតចេញពីគោលនយោបាយ និងសមិទ្ធិផលជាក់ស្តែងនៃការអភិវឌ្ឍន៍ជនបទរបស់រាជរដ្ឋាភិបាលបានឡើយ។

# ឧបសម្ព័ន្ធទី ១
# ទិន្នន័យរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា
# ឆ្នាំ ២០០៩

(សូមមើលឧបសម្ព័ន្ធទី ១ នៅផ្នែកភាសាអង់គ្លេស)

# ឧបសម្ព័ន្ធ២

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

ប្រចាំខែធ្នូ ឆ្នាំ២០០៩ (អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | | ឥណទានជាដុល្លារ | | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | 11.25% | 11.25% | 11.25% | 11.25% | | 11.25% | 11.25% | 11.25% | 11.25% |
| 2 | ធនាគារកាណាឌីយ៉ា ចំកាត់ | | 24.00% | 24.00% | 24.00% | 24.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 3 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | | | | | | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 4 | ធនាគារមេយប៊ែង | | | | | | | | | | 15.00% | | | | | |
| 5 | ធនាគារក្រុងថៃមហាជន ចំកាត់ | | | | | | | | | | 13.00% | | | | | 10.00% |
| 6 | ធនាគារ វឌ្ឍនៈ | | | | | | | 12.00% | 13.20% | 13.20% | 13.72% | | | | | |
| 7 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 8 | ធនាគារសាជីវកម្មសឹង្ហបុរី ចំកាត់ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 9 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 10 | ធនាគារមេគង្គកម្ពុជា | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 11 | ធនាគារសហពាណិជ្ជ ក.អ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 12 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | | | | | | | | | | 15.00% | | | | | |
| 13 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | | | | | | 14.00% | 15.00% | 16.00% | 18.00% | | | | | |
| 14 | ធនាគារពាណិជ្ជកម្មទី១ | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | | | | |
| 15 | ធនាគារអេស៊ីលីដា | | | | | 24.00% | | | | | 18.00% | | | | | 24.00% |
| 16 | ធនាគារ អេ អ៊ិន ហ្សេត រូយ៉ាល់ កម្ពុជា | | | | | | | | | | 10.50% | | | | | |
| 17 | ធនាគារខេមខូ លីមីតធីត | | | | | | | | | | 13.00% | | | | | |
| 18 | ធនាគារ អភិវឌ្ឍន៏និងវិនិយោគកម្ពុជា ភីអិលស៊ី | | | | | | | | | | 10.00% | | | | | |
| 19 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 20 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | | | | | | | 15.50% | 15.50% | 15.50% | 15.50% | | | | | |
| 21 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | | | 15.00% | | | | | |
| 22 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | | | | | 20.00% | | | | | |
| 23 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | | | | | 14.00% | | | | | 14.00% | | | | | |
| 24 | ធនាគារ អង្គរ កាពីតាល | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| 25 | ធនាគារសាខម | | 1.10% | 3.30% | 6.60% | 13.20% | | 1.10% | 3.30% | 6.60% | 13.20% | | | | | |
| 26 | ធនាគារឥណ្ឌា សាខាភ្នំពេញ | | | | | | | | | | 16.00% | | | | | |
| 27 | ធនាគារហុង ឡីប៊ីអេស | | | | | | | | | | 12.00% | | | | | |
| 28 | ធនាគារឯកទេស អានកូ | | | | | | | | | | 17.20% | | | | | |
| 29 | ធនាគារឯកទេសប៊ែស | | | | | | | | | | 18.12% | | | | | |
| 30 | ធនាគារឯកទេស ខេមបូឌាន ឌីវេឡុបមេន | | | | | | | | | | 15.00% | | | | | |
| 31 | ធនាគារឯកទេសវិនិយោគទីមួយ | | | | | | | | 18.00% | 18.00% | 18.00% | | | | | |
| 32 | ធនាគារឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| 33 | ធនាគារអភិវឌ្ឍន៏ជនបទ | | | | | 15.00% | | | | | 12.00% | | | | | |
| **មធ្យមក្រោយពេលថ្លឹង** | | | **22.66%** | **22.67%** | **22.68%** | **23.03%** | | **17.21%** | **17.15%** | **17.17%** | **16.40%** | | **11.25%** | **11.25%** | **11.25%** | **22.73%** |
| **មធ្យម** | | | **1.31%** | **1.37%** | **1.47%** | **3.28%** | | **6.03%** | **7.61%** | **7.74%** | **15.65%** | | **0.34%** | **0.34%** | **0.34%** | **1.37%** |

# ឧបសម្ព័ន្ធ២

## អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

**ប្រចាំខែធ្នូ ឆ្នាំ២០០៩** (អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | 0.25% | | 1.00% | | | 0.10% | | 1.00% | 1.00% | 1.00% | 0.10% | | 1.00% | | |
| 2 | ធនាគារកាណាឌីយ៉ា ចំកាត់ | 2.00% | | 5.00% | 6.00% | 7.00% | 0.75% | 3.00% | 4.00% | 4.75% | 6.00% | | | | | |
| 3 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | 1.00% | | | | | 1.00% | 3.25% | 4.00% | 4.75% | 6.00% | | | | | |
| 4 | ធនាគារមេយប៊ែង | | | | | | 1.00% | 2.00% | 2.25% | 2.75% | 3.75% | | | | | |
| 5 | ធនាគារក្រុងថៃមហាជន ចំកាត់ | | | | | | 0.10% | | 0.50% | 0.75% | 1.00% | | | | | |
| 6 | ធនាគារ វឌ្ឍនៈ | | | | | | 0.50% | 2.00% | 2.50% | 3.50% | 5.00% | | | | | |
| 7 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | 2.50% | 3.50% | 4.50% | 5.50% | 6.50% | | | | | |
| 8 | ធនាគារសាជីវកម្មសឹង្ហបុរី ចំកាត់ | | | | | | 0.50% | | 3.00% | 3.50% | 4.50% | | | | | |
| 9 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.50% | | 4.50% | 5.50% | 6.50% | 0.75% | 1.00% | 3.00% | 4.00% | 5.00% | | | | | |
| 10 | ធនាគារមេគង្គកម្ពុជា | 3.50% | | | | | 2.00% | 2.25% | 2.75% | 3.25% | 3.50% | 2.00% | | | | |
| 11 | ធនាគារសហពាណិជ្ជ ក.អ | | | | | | 1.00% | 3.50% | 4.50% | 5.50% | 6.50% | | | | | |
| 12 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | 3.00% | 3.75% | 5.00% | 6.00% | 7.00% | 3.00% | 3.75% | 5.00% | 6.00% | 7.00% | | | | | |
| 13 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | 1.00% | 4.00% | 4.50% | 6.00% | 7.00% | 1.00% | 4.00% | 4.50% | 6.00% | 7.00% | | | | | |
| 14 | ធនាគារពាណិជ្ជកម្មទី១ | | | | | | 0.40% | 1.25% | 1.35% | 1.45% | 1.55% | | | | | |
| 15 | ធនាគារអេស៊ីលីដា | 1.25% | 3.00% | 4.00% | 5.00% | 6.00% | 0.60% | 2.75% | 3.75% | 4.75% | 5.75% | 0.15% | 0.25% | 1.25% | 2.25% | 3.25% |
| 16 | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា | 0.50% | 3.55% | 3.70% | 4.60% | 6.70% | 0.25% | 3.35% | 4.00% | 4.50% | 5.00% | 0.15% | 0.35% | 0.75% | 0.90% | 1.05% |
| 17 | ធនាគារខេមខូ លីមីតធីត | | | | | | 1.00% | 3.50% | 4.00% | 5.00% | 6.00% | | | | | |
| 18 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | 2.00% | 3.55% | 4.60% | 5.55% | 6.50% | 2.00% | 3.00% | 4.00% | 4.75% | 6.00% | | | | | |
| 19 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | 0.50% | 2.25% | 2.65% | 2.80% | 3.00% | | | | | |
| 20 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 1.00% | | | | | 0.50% | 2.55% | 3.20% | 3.90% | 4.75% | | | | | |
| 21 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.00% | | | | | 1.00% | 3.00% | 4.00% | 5.00% | 6.00% | | | | | |
| 22 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | 1.20% | 3.70% | 4.20% | 5.20% | 6.20% | | | | | |
| 23 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 2.25% | 4.00% | 4.50% | 5.00% | 6.50% | | | | | |
| 24 | ធនាគារ អង្គរ កាពីតាល | | | | | | 2.00% | 5.25% | 6.00% | 6.50% | 7.50% | | | | | |
| 25 | ធនាគារសាខម | 1.00% | 4.00% | 5.00% | 6.00% | 7.00% | 0.50% | 3.50% | 4.50% | 5.50% | 6.00% | | | | | |
| 26 | ធនាគារឥណ្ឌា សាខាភ្នំពេញ | | | | | | 0.75% | 1.00% | 1.50% | 2.25% | | | | | | |
| 27 | ធនាគារហ្វុង ឌីប៊ីអេស | | | | | | 1.00% | 3.50% | 4.50% | 5.50% | 6.50% | | | | | |
| 28 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 29 | ធនាគារឯកទេសប៉េស | | | | | | | | | | | | | | | |
| 30 | ធនាគារឯកទេស ខេមបូឌាន ឌីវេឡុបមេន | | | | | | | | | | | | | | | |
| 31 | ធនាគារឯកទេសវិនិយោគទីមួយ | | | | | | | | | | | | | | | |
| 32 | ធនាគារឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | | | | | | | | | |
| 33 | ធនាគារអភិវឌ្ឍន៍ជនបទ | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.00% | 3.00% | 3.50% | 4.00% | 5.00% | | | | | |
| **មធ្យមភាគក្រោយការថ្លឹង** | | **1.23%** | **3.25%** | **4.11%** | **5.28%** | **6.53%** | **0.71%** | **2.84%** | **3.59%** | **4.35%** | **5.33%** | **0.17%** | **0.29%** | **1.05%** | **1.72%** | **2.39%** |
| **មធ្យមភាគ** | | **0.67%** | **0.87%** | **1.37%** | **1.66%** | **1.99%** | **0.88%** | **2.24%** | **2.94%** | **3.56%** | **4.20%** | **0.07%** | **0.02%** | **0.09%** | **0.10%** | **0.13%** |

# ឧបសម្ព័ន្ធទី ៣: ប្រព័ន្ធធនាគារកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៩

## ធនាគារជាតិ នៃកម្ពុជា

### ២៧ ធនាគារពាណិជ្ជ

#### ៥ សាខាធនាគារបរទេស

-ធនាគារ ពាណិជ្ជកម្មទីមួយ
-ធនាគារ ក្រុងថៃ
-ធនាគារ មេយបែង
-ធនាគារ សាខម
-ធនាគារ ឥណ្ឌា សាខាភ្នំពេញ

#### ២២ បង្កើតឡើងតាមច្បាប់ក្នុងស្រុក

-ធនាគារពាណិជ្ជកម្មក្រៅប្រទេស
-ធនាគារ វឌ្ឍនៈអាស៊ី
-ធនាគារ កម្ពុជាអាស៊ី
-ធនាគារ កាណាឌីយ៉ា
-ធនាគារ កម្ពុជាពាណិជ្ជ
-ធនាគារ កម្ពុជាមេគង្គ
-ធនាគារ កម្ពុជាសាធារណៈ
-សាជីវកម្ម ធនាគារ សិង្ហបូរី
-ធនាគារ សហពាណិជ្ជ
-ធនាគារ វឌ្ឍនៈ
-ធនាគារ អេស៊ីលីដា
-ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់
-ធនាគារខេមខូ
-ធនាគារ ស៊ិនហាន ខ្មែរ
-ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា
-ម៉ារ៉ូហាន់ ធនាគារ ជប៉ុន
-ធនាគារខ្មែរយូញៀន
-ធនាគារប៊ូយ៉ុងខ្មែរ
-ធនាគារភ្នំពេញពាណិជ្ជ
-ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា
-ធនាគារ អង្គរកាពីតាល់
-ធនាគារ ហ្វុង ឌី ប៊ី អេស ពាណិជ្ជ

• បើកជាផ្លូវការ

### ៦ ធនាគារឯកទេស

#### ១ ធនាគាររដ្ឋ

-ធនាគារ អភិវឌ្ឍន៍ជនបទ

#### ៥ ធនាគារឯកជន

-ធនាគារ ឯកទេស P.H.S.M.E
-ធនាគារឯកទេសវិនិយោគទីមួយ
-ធនាគារ ឯកទេសអានកូ
-ធនាគារ ឯកទេសខេមបូឌាន ឌីវីឡុបមេន
-ធនាគារឯកទេស ប៊េស

### • ២ ការិយាល័យតំណាង

- ស្តង់ដារឆាទីរ៉ែត
- ធនាគារកសិកម្មនិងអភិវឌ្ឍន៍នៃវៀតណាម

### គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

#### • ២០ មានអាជ្ញាប័ណ្ណ

1- អម្រឹត
2-ហត្ថាកសិករ
3-តុងហ្វាងមីក្រូហិរញ្ញវត្ថុ
4-ធនាគារភូមិកម្ពុជា
5-សិលានិធិ
6-ក្រុមហ៊ុនស្ថាបនាសហគ្រិនកម្ពុជា
7-ក្រុមហ៊ុនអង្គរមីក្រូហិរញ្ញវត្ថុ
8-វីសុនហ្វាន់(ខេមបូឌា)
9-ក្រុមហ៊ុនក្រេឌីត Co.Ltd.
10-ប្រាសាក់ ម៉ាយក្រូហ្វាយនែន
11-សមាគមមូលនិធិសហភាពអភិ.កសិករ
12-ក្រុមហ៊ុនអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា
13-ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ
14-ឥណទានពលរដ្ឋរុងរឿង
15- ហ្វឹស ហ្វាយនែន
16- ហ្វាមើរ ហ្វាយនែន
17. ឥណទានអភិវឌ្ឍន៍ប្រជាជន
18- ហ្វ្រិន សេនត្រស ម៉ាយក្រូហ្វាយនែន
19. សាមិក
20- វ៉ាយ ស៊ី ភី

#### អង្គការក្រៅរដ្ឋាភិបាល

• ២៦ ចុះបញ្ជី *

• មិនចុះបញ្ជីមានប្រហែល៦០ទៀត

### ២១សាខាធនាគារជាតិនៅតាមខេត្ត

-ក្រុងភ្នំពេញ
-កំពង់ចាម
-ក្រុងព្រះសីហនុ
-សៀមរាប
-បាត់ដំបង
-ស្វាយរៀង
-កំពត
-កណ្ដាល
-កំពង់ធំ
-ពោធិសាត់
-កំពង់ស្ពឺ
-កោះកុង
-រតនៈគីរី
-មណ្ឌលគីរី
-ព្រៃវែង
-តាកែវ
-កំពង់ឆ្នាំង
-ព្រះវិហារ
-ក្រចេះ
-ស្ទឹងត្រែង
-បន្ទាយមានជ័យ

### អាជីវកម្មប្តូរប្រាក់

• ចុះបញ្ជីខេត្ត/ក្រុង ៧៩៥

## *អង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីចំនួន ២៦

| | | | |
|---|---|---|---|
| 1 | សមាគមអភិវឌ្ឍន៍កសិកម្ម និងទេសចរណ៍ | 14 | សមាគមជាតិទ្រទ្រង់កសិផល |
| 2 | សមាគមជួយកសិករ | 15 | អង្គការ អភិវឌ្ឍន៍របរចិញ្ចឹមជីវិតកសិករ |
| 3 | សមាគមផ្ដើមគំនិតពាណិជ្ជកម្ម | 16 | អង្គការអភិវឌ្ឍន៍ជនបទខ្មែរ |
| 4 | សមាគមសំណាងអភិវឌ្ឍន៍ជនបទ | 17 | សមាគមសុខមាលភាពស្ត្រីខេត្តក្រចេះ |
| 5 | ស៊ី អាយ ស៊ី អេម កម្ពុជា | 18 | អង្គការលូថេរ៉ាន បំរើពិភពលោក |
| 6 | អង្គការឥណទានលុបបំបាត់ភាពក្រីក្រកម្ពុជា | 19 | គំរោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ |
| 7 | អង្គការបណ្ដាញសេដ្ឋកិច្ចកម្ពុជា | 20 | អង្គការក្រុមការងារសេដ្ឋកិច្ចថ្មី |
| 8 | អង្គការសង្គហអភិវឌ្ឍន៍កម្ពុជា | 21 | សមាគមអភិវឌ្ឍន៍តំបន់ពាយ័ព្យ |
| 9 | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅកម្ពុជា | 22 | វិទ្យាស្ថានសន្តិភាព និងអភិវឌ្ឍន៍ |
| 10 | សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា | 23 | អង្គការ សប្បុរស |
| 11 | អង្គការ ច័ន្ទ សុខសាន្ត | 24 | អង្គការអភិវឌ្ឍន៍សង្គមជនបទ |
| 12 | អង្គការ ចំរើន មីក្រូហិរញ្ញវត្ថុ | 25 | អង្គការពន្លឺព្រះអាទិត្យរះ |
| 13 | អង្គការទ្រទ្រង់សហគមន៍បង្កើនអភិវឌ្ឍន៍ | 26 | សមាគមអភិវឌ្ឍន៍សណ្ដែកសៀងតាអុង |